**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក- (អ.ជ.ស.ប.)

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: **បារាំង**

កាលបរិច្ឆេទឯកសារ: ៥ កក្កដា ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ (ឧបសម្ព័ន្ធសម្ងាត់)**

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ប៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 07-Jul-2011, 10:32
CMS/CFO: Ly Bunloung

---

**សំណើសុំដាក់បន្ថែមសាក្សីទៅក្នុងបញ្ជីឈ្មោះបណ្ដោះអាសន្ន សម្រាប់ដំណាក់កាលដំបូងៗនៃការជំនុំជម្រះ**

---

ដាក់ដោយ៖

**សហមេធាវីការពារក្តីលោក ខៀវ សំផន**

លោក ស សូវ៉ាន

លោក Jacques VERGES

**អ្នកជំនួយការ**

លោកស្រី សេង សុជាតា

លោកស្រី Marie CAPOTORTO

លោក Shéhérazade BOUARFA

លោក Archibald CELEYRON

ផ្ញើជូន៖

**អង្គបុរេជំនុំជម្រះ**

ចៅក្រម និល ណុន

ចៅក្រម ធូ មណី

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម Silvia CARTWRIGHT

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew CAYLEY

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី Elisabeth SIMONNEAU FORT

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

## I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីនៃសំណុំរឿង ០០២ អំពីបញ្ជីឈ្មោះបណ្តោះអាសន្នរបស់សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលអង្គជំនុំជម្រះសាលាដំបូងមានបំណងកោះហៅឲ្យចូលខ្លួនមកបង្ហាញខ្លួន នៅក្នុងដំណាក់កាលទាំងបួនដំបូងនៃការជំនុំជម្រះ[1]។

២. ដោយយល់ឃើញថា បញ្ជីឈ្មោះនេះជាបញ្ជីឈ្មោះបណ្តោះអាសន្ន ហើយក្នុងតំណាក់កាលនេះ ពុំមានសាក្សីណាមួយត្រូវបានបដិសេធចោល[2] អង្គជំនុំជម្រះសាលាដំបូងបានទុកលទ្ធភាពឲ្យភាគីក្នុងការដាក់សាក្សីបន្ថែមចូលទៅក្នុងបញ្ជីឈ្មោះនេះ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ៥ ខែ កក្កដា[3] ពោលគឺ "ធ្វើយ៉ាងណាដើម្បីធានាបានថា ពុំមានសាក្សីណាម្នាក់ ឬអ្នកជំនាញសំខាន់ និងសំខាន់បំផុតណាម្នាក់ ត្រូវបានគេភ្លេចដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះនោះឡើយ"[4]។

៣. ពេលនេះ លោក ខៀវ សំផន សូមជូនដំណឹងអំពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែលលោកយល់ឃើញថាវាមានសារៈសំខាន់ ដោយផ្តល់នូវហេតុផលយ៉ាងខ្លីនៅក្នុងផ្នែកនៃឧបសម្ពន្ធទាក់ទងនឹងបញ្ជីឈ្មោះនេះ។

## II. កិច្ចពិភាក្សា

---

[1] អត្ថបទប្រតិចារឹកសវនាការ សំណៅមិនទាន់កែសម្រួល ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ៨ និង ៩។

[2] អត្ថបទប្រតិចារឹកសវនាការ សំណៅមិនទាន់កែសម្រួល ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ១ L. ១១ ដល់១៦ និង២០ ដល់ ២២។

[3] អត្ថបទប្រតិចារឹកសវនាការ សំណៅមិនទាន់កែសម្រួល ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ២ L.២៤ ទំព័រ៥១ L. ២២។

[4] អត្ថបទប្រតិចារឹកសវនាការ សំណៅមិនទាន់កែសម្រួល ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ២ L.២០ ដល់២៥ និងទំព័រ ៣ L. ១ ដល់៣។

Original FR: 00711687-00711690

៤. ដូចដែលបានលើកឡើងនៅក្នុងអង្គសវនាការរួចមកហើយ[5] លោក ខៀវ សំផន បានធ្វើការសន្និដ្ឋានថា សាក្សីមួយភាគធំដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះ គឺជាសាក្សីដែលបានជ្រើសរើសដោយភាគីសហព្រះរាជអាជ្ញា (ដែលមានចំនួនរហូតដល់ ៩៣,៧៥ ភាគរយ)[6]។

៥. លោក ខៀវ សំផន ក៏បានបញ្ជាក់ឲ្យដឹងផងដែរថា លោកនឹងធ្វើការសហការយ៉ាងពេញទំហឹងជាមួយអង្គជំនុំជម្រះ ក្នុងកិច្ចដំណើរការស្វែងរកការពិត។ ក៏ប៉ុន្តែ ដើម្បីសម្រេចគោលដៅនេះ វាជាការចាំបាច់ដែលអង្គជំនុំជម្រះត្រូវស្ដាប់សក្ខីកម្មរបស់សាក្សី ដែលលោកស្នើឡើងនោះ។

៦. ពិតមែនតែអង្គជំនុំជម្រះបានបញ្ជាក់ជាច្រើនលើកច្រើនសាហើយថា ពុំមានសាក្សីណាម្នាក់ត្រូវបានគេបដិសេធចោលឡើយ[7]។ ក៏ប៉ុន្តែ វាជាការលំបាកខ្លាំងណាស់ក្នុងការរំពឹងទុកថា សាក្សីដែលពុំមានឈ្មោះក្នុងបញ្ជីឈ្មោះបណ្ដោះអាសន្នរបស់អង្គជំនុំជម្រះ នឹងអាចមានឱកាសផ្ដល់សក្ខីកម្មនៅក្នុងតំណាក់កាលក្រោយៗនៃការជំនុំជម្រះ ក្នុងខណៈដែលពុំមានការបញ្ជាក់ណាមួយអំពីចំនួនរបស់ពួកគេ និងខ្លឹមសារនៃសក្ខីកម្មដែលពួកគេត្រូវផ្ដល់នោះ។

៧. វាអាចថា សាក្សីមួយចំនួនដែលបានស្នើឡើងដោយលោក ខៀវ សំផន មានលក្ខណៈសមហេតុសមផលសម្រាប់ដំណាក់កាលក្រោយៗនៃការជំនុំជម្រះសេចក្ដី។ ជាក់ស្ដែង សាក្សីទាំងនោះបានបង្ហាញនូវសារៈសំខាន់របស់ខ្លួនរួចទៅហើយនៅក្នុងដំណាក់កាលទាំងបួនដំបូងនៃការជំនុំជម្រះនោះ[8]។

---

[5] អត្ថបទប្រតិចារឹកសវនាការ សំណៅមិនទាន់កែសម្រួល ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ២៣ ដល់២៥។

[6] ទាក់ទងចំនួនសរុបនៃសាក្សី ដើមបណ្ដឹងរដ្ឋប្បវេណី និងអ្នកជំនាញ៖ **៩៤,៦៤% ត្រូវបានបញ្ជាក់ដោយភាគីសហព្រះរាជ អាជ្ញា**។

[7] អត្ថបទប្រតិចារឹកសវនាការ សំណៅមិនទាន់កែសម្រួល ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ទំព័រ ១ L. ១១ ដល់១៦។

[8] ដំណាក់កាលទាំងបួនដំបូងនៃការជំនុំជម្រះក្ដីគឺ៖ ១). ទម្រង់នៃកម្ពុជាប្រជាធិបតេយ្យ ២). តួនាទីរបស់ជនជាប់ចោទម្នាក់ៗនៅក្នុងសម័យមុនការកើតមាននូវរបបកម្ពុជាប្រជាធិបតេយ្យ ដោយគិតទាំងកាលបរិច្ឆេទនៃការប្រគល់តួនាទីទាំងនោះដល់ពួកគេផងដែរ ៣). តួនាទីរបស់ជនជាប់ចោទម្នាក់ៗក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ពួកគេម្នាក់ៗ វិសាលភាពនៃអំណាចរបស់ពួកគេ និងខ្សែរយៈទាក់ទងពេញមួយសម័យកាលនោះ ដែលស្ថិតក្រោមយុត្តាធិការតាមពេលវេលា (*rationae temporis*) របស់ អវតក និង ៤). គោលនយោបាយដែលត្រូវបានអនុម័ត និងអនុវត្តដោយរបបកម្ពុជាប្រជាធិបតេយ្យ នៅក្នុងវិស័យទាំងឡាយដែលបានកំណត់ដោយដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ សូមពិនិត្យមើលជាឧទាហរណ៍ "អនុសាសន៍ដែលផ្ដល់សម្រាប់ការត្រៀមរៀបចំសវនាការបឋម និងដែលពាក់ព័ន្ធទៅនឹងបញ្ជីឈ្មោះសាក្សីដែលបានស្នើឡើង" ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E93 ឬ T. ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ ៥៣ និង ៥៤។

Original FR: 00711687-00711690

៨. លោក ខៀវ សំផន បានបង្ហាញនូវហេតុផលរបស់លោកយ៉ាងខ្លីពាក់ព័ន្ធទៅនឹងសាក្សី ទាំងសាក្សីដែលបានស្តាប់យកចម្លើយដោយសហចៅក្រមស៊ើបអង្កេតរួចហើយ (ឧបសម្ព័ន្ធ ១) ទាំងសាក្សីដែលពុំទាន់ត្រូវបានស្តាប់យកចម្លើយ (ឧបសម្ព័ន្ធ ២)។

៩. អង្គជំនុំជម្រះសាលាដំបូងនឹងអាចសន្និដ្ឋានថា សាក្សីទាំងឡាយដែលមានឈ្មោះក្នុងបញ្ជីនៃឧបសម្ព័ន្ធ ១ ពុំត្រូវបានបដិសេធដោយសហព្រះរាជអាជ្ញាឡើយ។ ដោយឡែក សាក្សីមួយចំនួនតូចដែលមានឈ្មោះក្នុងបញ្ជីនៃឧបសម្ព័ន្ធ ២ ត្រូវបានបដិសេធដោយសហព្រះរាជអាជ្ញា។ ម្យ៉ាងទៀត សហព្រះរាជអាជ្ញាបានឯកភាពថា សាក្សី និងអ្នកជំនាញទាំងឡាយដែលបានស្នើឡើងដោយលោក ខៀវ សំផន ហើយដែលសហព្រះរាជអាជ្ញាពុំបានធ្វើការបដិសេធ "អាចនឹងផ្តល់នូវមូលដ្ឋានភស្តុតាងសមស្រប និងគួរឲ្យជឿបាន ពាក់ព័ន្ធទៅនឹងអង្គហេតុសំខាន់ៗដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[9]។

១០. អង្គជំនុំជម្រះសាលាដំបូងប្រហែលជានឹងអាចវាយតម្លៃបានថា សាក្សីមួយចំនួនក្នុងចំណោមសាក្សីទាំងនោះអាចនឹងរឹតតែមានសារៈសំខាន់ សម្រាប់ដំណាក់កាលនៃការជំនុំជម្រះក្រោយៗ ដោយមានតែអង្គជំនុំជម្រះមួយគត់ដែលអាចដឹងអំពីបញ្ហានេះ។ ក្នុងកាលៈទេសៈណាក៏ដោយ សាក្សីទាំងនេះត្រូវតែបានធ្វើការស្តាប់យកចម្លើយ ដើម្បីធានា ឲ្យការកាត់សេចក្តីប្រព្រឹត្តទៅបានល្អ និងប្រកបដោយយុត្តិធម៌។

## ហេតុដូច្នេះ

១១. សហមេធាវីការពារក្តីលោក ខៀវ សំផន សូមស្នើដល់អង្គជំនុំជម្រះសាលាដំបូងមេត្តា៖

ដាក់បន្ថែមសាក្សីទាំងឡាយដែលបានស្នើឡើងដោយលោក ខៀវ សំផន ទៅក្នុងបញ្ជីឈ្មោះបណ្តោះអាសន្ន ទាក់ទងទៅនឹងដំណាក់កាលទាំងបួនដំបូងនៃការជំនុំជម្រះ ហើយធ្វើការកោះហៅសាក្សីទាំងនោះឲ្យចូលមកបង្ហាញខ្លួនក្នុងដំណាក់កាលក្រោយៗនៃសវនាការជំនុំជម្រះ។

---

[9] " អញ្ញត្រកម្មរបស់សហព្រះរាជអាជ្ញា ដែលតាមរយៈនេះ សហព្រះរាជអាជ្ញាបានជំទាស់ទៅនឹងសំណើសុំឲ្យមានការចូលខ្លួនរបស់អ្នកជំនាញ និងសាក្សីមួយចំនួន ធ្វើឡើងដោយភាគីដទៃទៀត ដោយមាន ១១ ឧបសម្ព័ន្ធសម្ងាត់" ថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១១។ ឯកសារលេខ D9/14/1/1។ កថាខណ្ឌ ៣៩។

Original FR: 00711687-00711690

# អង្គជំនុំជម្រះសាលាដំបូង

## និងដើម្បីយុត្តិធម៌

| | | | |
|---|---|---|---|
| | មេធាវី សរ សុវាន<br><br>មេធាវី Jacques VERGÈS | ភ្នំពេញ<br><br>ប៉ារីស | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

Original FR: 00711687-00711690